# បុណ្យនាំឲ្យរីករាយ

## បាបនាំឲ្យវិនាសនាំឲ្យកើតទុក្ខ *(បទពាក្យ ៧)*

*ធម៌ទាំងឡាយមានចិត្តជាធំ ប្រសើរឧត្តមស្រេចដោយចិត្ត*
*កាយធ្វើមាត់ពោលផ្លូវទុច្ចរិត មានចិត្តប្រទូស្តទើបធ្វើបាន ។*
*ផលបាបអន្ទោលតាមជននោះ ដូចកង់រទេះវិលតាមដាន*
*ជើងគោដែលអូសមិនមានខាន រងទុក្ខឥតក្សាន្តតាមកម្មពិត ។*
*ធម៌ទាំងឡាយមានចិត្តជាធំ ប្រសើរឧត្តមស្រេចដោយចិត្ត*
*កាយធ្វើមាត់ពោលផ្លូវសុចរិត មានចិត្តជ្រះថ្លាទើបធ្វើបាន ។*
*ផលបុណ្យតាមជននោះអន្ទោល ប្រៀបដូចស្រមោលទៅតាមប្រាណ*
*ទោះកើតជាតិណាភពណាបាន សោយសុខក្សេមក្សាន្តយ៉ាងជាក់ស្តែង។*
*ជនណាចងពៀរវេរាជាក់ អ្នកនោះវាយធាក់ជេរអញឯង*
*បានឈ្នះបានលួចទ្រព្យផ្សេងៗ ពៀរនោះឆ្ងាយវែងមិនរម្ងាប់ ។*
*អ្នកមិនចងពៀរវេរាជាក់ គេជេរគេធាក់បោកយកទ្រព្យ*
*គេឈ្នះយ៉ាងណាមិនកាន់ខ្ជាប់ ពៀរនោះរម្ងាប់បានដោយងាយ ។*
*ពៀរមិនរម្ងាប់ដោយពៀរទេ ក្នុងលោកទាំងទ្វេជាសម្មាយ*
*បើមិនចងពៀរអាចស្ងប់ងាយ ធម៌នោះព្រេងនាយមានតជាប់ ។*
*ក្រុមជនដទៃមិនដឹងពិត ថាយើងត្រូវបិតក្នុងថ្ងៃស្លាប់*
*ជនណាបានដឹងពិសេសគាប់ វិវាទស្ងប់ដោយដឹងនោះនៃ ។*

អ្នកស្វែងសប្បាយព្រោះឃើញល្អ នៅក្នុងរូបធម៌ជនប្រុសស្រី
គ្មានការសង្រួមឥន្ទ្រីយ៍ខ្មី បរិភោគចំណីមិនប្រមាណ ។
អ្នកខ្ជិលច្រអូសគ្មានព្យាយាម មារតាមគំរាមផ្ចាញ់ងាយបាន
ដូចព្យុះផ្តួលឈើពុកដើមដាន ឲ្យដួលចាកឋានងាយឥតបី ។
ឃើញនូវអារម្មណ៍ថាមិនល្អ នៅក្នុងរូបធម៌ជនប្រុសស្រី
ឥន្ទ្រីយ៍សង្រួមដោយប្រពៃ បរិភោគចំណីមានកំណត់ ។
អ្នកមានសទ្ធាហើយឧស្សាហ៍ ប្រតិបត្តិធម៌អាថ៌យ៉ាងប្ញាត់ចត់
មារផ្ចាញ់មិនបានជាកំណត់ ថ្មភ្នំប្រាកដឈ្នះខ្យល់បាន ។
ជនណាប្រើប្រាស់កាសាវៈ គ្មានទម្មៈសច្ចៈនៅក្នុងប្រាណ
កិលេសរួបរឹតក្នុងសន្តាន មិនគួរប្រើប្រាស់កាសាវៈ ។
ជនណាស្លៀកពាក់គ្រឿងអរម្មត់ អនុវត្តនូវសីលប្រពៃជាក់
ប្រើពាក្យសត្យសង្រួមមានទម្មៈ ប្រើកាសាវៈសមបវរ ។
គោចរមិនមានដល់ជនណា ធម៌គ្មានខ្លឹមសារថាខ្លឹមធម៌
ឆ្ពោះសារៈធម៌ថាមិនល្អ ត្រិះរិះខុសធម៌យកជាមគ្គ ។
គោចរតែងមានដល់ពួកជន ស្គាល់ទាន់សារៈអសារៈ
ឃើញត្រូវយល់ត្រូវទុកជាមគ្គ បានសម្រេចជាក់ធម៌ខ្លឹមសារ ។
ផ្ទះណាដែលប្រក់ប្រាំមិនជិត ទឹកភ្លៀងលេចពិតចូលយ៉ាងណា
ចិត្តគ្មានភាវនា ចិត្តសាវ៉ា រាគរោលកាយាទុក្ខរឿយ ៗ ។

ផ្ទះណាដែលគេប្រក់ព្រំស្អាត ទឹកភ្លៀងចូលជ្រៀតមិនបានឡើយ
ចិត្តដែលចំរើនស្អាតល្អហើយ រាគៈមិនរោលយ៉ាងនោះឯង ។
អ្នកដែលធ្វើបាបតែងសោយសោក ក្នុងលោកទាំងពីរយ៉ាងសង្រេង
ជាតិនេះជាតិមុខទៀតមិនលែង ឃើញកម្មខ្លួនឯងវែងអបលក្ខណ៍។
អ្នកដែលធ្វើបុណ្យតែងរីករាយ ក្នុងលោកទាំងឡាយយ៉ាងទៀងជាក់
ជាតិនេះជាតិមុខទៀតឥតអាក់ ឃើញបុណ្យខ្លួនអ្នកល្អពន់ពេក ។
អ្នកបាបតែងក្តួលក្តៅឥន្ទ្រីយ៍ ក្នុងលោកទាំងពីរយ៉ាងអនេក
ជាតិនេះជាតិក្រោយក្តៅចម្លែក ក្តៅប្លែកក្នុងឋានអបាយបួន ។
អ្នកបុណ្យសប្បាយចិត្តពេញទី ក្នុងលោកទាំងពីរយ៉ាងសមសួន
ជាតិនេះជាតិក្រោយសុខស្រួលខ្លួន សុខត្រួតផ្ទួន ៗ ក្នុងសួគ៌ា ។
អ្នកខ្លះនិយាយធម៌ច្រើនពិត តែមិនប្រព្រឹត្តតាមវាចា
ប្រមាទហើយគ្មានពិចារណា ប្រៀបថាគង្វាលឃ្វាលយកប្រាក់ ។
រាប់ចំនួនគោគេទៀងទាត់ ខ្លាចបាត់គោគេមានគ្រោះថ្នាក់
ថ្លៃគោ ទឹកដោះគ្មានបានជាក់ ជាអ្នកគ្មានភាគសាមញ្ញផល ។
អ្នកប្រព្រឹត្តធម៌ គួរដល់ធម៌ សូត្រធម៌ទោះតិចក៏គួរដល់
រាគៈទោសៈមេអកុសល មោហៈបូសគល់លះចោលបាន។
យល់ធម៌ប្រពៃចិត្តស្រឡះ ខំលះរួចចាកឧបាទាន
ចំណែកសាមញ្ញផលមាន សោយសុខក្នុងឋានលោកទាំងពីរ ៕